**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១០

លេខ៖ 3789 កបទ៦ច្បក.អស.

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ៖** *ករណីលើកលែងតំលៃទិដ្ឋាការប្រភេទទេសចរណ៍*

**យោង៖** *-កំណត់ទូតលេខ 08001/207 ចុះថ្ងៃទី ០៣-០៥-១០ របស់**ស្ថានទូតថៃប្រចាំនៅប្រទេសកម្ពុជា***

- *លិខិតលេខ ៥៤៤៤ កបទ.សអ.ច្បក៦ ចុះថ្ងៃទី ២៩-០៦-១០ របស់**ក្រសួងការបរទេស និង សហប្រត្តិការអន្តរជាតិ***

*ខ្ញុំសូមជំរាបជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប រដ្ឋាភិបាលថៃបានសំរេចបន្ត**ពន្យាការលើកលែងតំលៃទិដ្ឋាការប្រភេទទេសចរណ៍** ចាប់ពីថ្ងៃទិ **១១ ឧសភា ២០១០** រហូតដល់ **៣១ មីនា ២០១១** ដល់អ្នកទេសចរណ៍បរទេសទាំងអស់ ដែលសុំទិដ្ឋាការប្រភេទទេសចរណ៍ចូល**ប្រទេសថៃ** នៅតាមបណ្តាស្ថានទូត និង ស្ថានអគ្គកុងស៊ុល ថៃប្រចាំនៅបរទេស ។*

*ការមិនយកតំលៃទិដ្ឋាការនេះនៅតែតំរូវអោយអ្នកស្នើសុំទៅសុំទិដ្ឋាការដដែលនៅស្ថានទូតថៃ ។*

*ចំពោះទិដ្ឋាការមិនមែនអន្តោប្រវេសន៍ ( Non-immigrant ) និងទិដ្ឋាការឆ្លងកាត់ ( Transit ) ត្រូវតែបង់ថ្លៃទិដ្ឋាការដដែល ។*

*សូម **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និង ចាត់វិធានការ តាមការគួរ ។*

ចំលងជូន៖

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័ន*

**ឡុង វិសាលោ**